ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការក្រុងព្រះសីហនុ

សាលក្រម
លេខ ១១២ ចុះថ្ងៃទី ១៦
ខែ ធ្នូ ឆ្នាំ ២០០៤

សំណុំរឿងព្រហ្មទណ្ឌ
លេខ ៩៨ ចុះថ្ងៃទី ០៤
ខែ មិថុនា ឆ្នាំ ២០០៤

សាលក្រមនេះចូលស្ថាពរហើយ
ក្រុងព្រះសីហនុថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០៥
ក្រឡាបញ្ជី [redacted]

## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការក្រុងព្រះសីហនុ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី នៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើដោយក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ បានបើកសវនាការជាសាធារណៈនៅតុលាការក្រុងព្រះសីហនុ នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៤ ដោយមានសមាសភាពដូចតទៅ :

**- ចៅក្រមជំនុំជំរះ**

លោក [redacted] អនុប្រធានតុលាការក្រុងព្រះសីហនុ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងស្តីទីអមតុលាការក្រុងព្រះសីហនុ

**ក្រឡាបញ្ជីសវនាការ**

លោក គៀង សុន្ទរោ

**មេធាវីការពារ**

លោក [redacted]វុនធី

ដើម្បីជំនុំជំរះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៩៧ ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៤ ដែលមានជនជាប់ចោទឈ្មោះ :

១-ឈ្មោះ **ហ ចន** ភេទប្រុស អាយុ ៥៦ឆ្នាំ ជាតិខ្មែរ កើតនៅភូមិឈើកាច់ ឃុំឈើកាច់ ស្រុកបាភ្នំ ខេត្តព្រៃវែង ទីលំនៅសព្វថ្ងៃក្រុម ១៥ ភូមិ២ សង្កាត់៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ របររកស៊ីបើកបររថយន្តឈ្នួល ឪពុកឈ្មោះ **ហ ស** (ស) ម្តាយឈ្មោះ **អ យ** (ស) ប្រពន្ធឈ្មោះ **អ ម** មានកូន ០៤នាក់ ទោសពីមុន *គ្មាន* ចាប់ខ្លួនថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ ឃុំខ្លួនថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០៤ ។

-ត្រូវជាប់ចោទពីបទ " **បង្ករបួសដោយចេតនា** " ប្រព្រឹត្តនៅភូមិ២ សង្កាត់៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និង ឱ្យផ្តន្ទាទោស តាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាល ។

-ឈ្មោះ **អ ម** ភេទស្រី អាយុ ៥០ឆ្នាំ ជាតិខ្មែរ របររកស៊ីព្រួឡាន មានទីលំនៅសព្វថ្ងៃភូមិ **២** សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ជាជនរងគ្រោះ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៤២៧ ដសព.០៤ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់តំណាងអយ្យការអមតុលាការក្រុងព្រះសីហនុ ។

-បានឃើញដីកាបញ្ជូនរឿងជំនុំជំរះលេខ ១១៧ ត.ព.០៤ ចុះថ្ងៃទិ ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់ចៅក្រមស៊ើបអង្កេតនៃតុលាការក្រុងព្រះសីហនុ ។

CamScanner

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ១២៣៦ តព.០៤ ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ របស់ប្រធានតុលាការក្រុងព្រះសីហនុ ។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ :

-កាលពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ ឈ្មោះ **ហ ចន** បានទៅផ្ទះបងថ្លៃខ្លួនក្នុងគោលបំណង ដើម្បីសុំលុយប្រពន្ធចាយ និង ទិញអង្ករហូប ពេលទៅដល់សុំលុយប្រពន្ធមិនបានក៏បានប្រតាយលូកហោប៉ៅអាវប្រពន្ធ ដើម្បីយកប្រាក់ តែនៅដៃរបស់ឈ្មោះ **ហ ចន** មានកាន់ផ្លែឡាមចំនួន ១ សំរាប់កោរពុកមាត់ បណ្តាលឱ្យមុតដោះប្រពន្ធជាច្រើនកន្លែង ក៏ប្តឹងសមត្ថកិច្ចចាប់ខ្លួនឈ្មោះ **ហ ចន** នោះទៅ ។

## នាពេលសួរចម្លើយ

-ឈ្មោះ **ហ ចន** ជាជនជាប់ចោទបានឆ្លើយថា ខ្លួន និង **អ ម** ជាប្តី និង ប្រពន្ធគ្នា តែកន្លងមកឧស្សាហ៍ឈ្លោះគ្នាជាញឹកញាប់ ដោយសារតែការប្រច័ណ្ឌ ហើយប្រពន្ធខ្លួនបានធ្វើបាបខ្លួនជាញឹកញាប់ ដោយមួយរយៈកន្លងមកគាត់ជាអ្នកកាន់លុយ និង ជាអ្នកធ្វើព្រួឡានឱ្យខ្លួន ពេលឡានខូចម្តងៗសុំលុយពីគាត់ ដើម្បីយកឡានទៅជួសជុលគាត់ថា អស់លុយហើយ ខ្លួនដឹងថា លុយសល់ពីរត់ឡាន ទើបតែបានពីពេលថ្ងៃហ៊ីងរឿងអីអស់លុយលឿនម្ល៉េះ ខ្លួនចេះតែដើរខ្ចីលុយគេឯង ដើម្បីជួសជុលរថយន្ត ហើយក៏ចេះតែឧស្សាហ៍ឈ្លោះគ្នាទៅ ។ គាត់ក៏ចុះចេញពីលើផ្ទះទៅរស់នៅជាមួយប្អូនគាត់នៅម្តុំសេតេ ពេលនោះឡានគ្មានលុយជួសជុលមិនដំណើរការ អង្ករក៏គ្មានហូប លុយកាក់ក៏គ្មាន ខ្លួនក៏ធ្វើដំណើរទៅផ្ទះបងប្អូនខាងប្រពន្ធក្នុងគោលបំណងសុំលុយគាត់ ដើម្បីយកទៅទិញអង្ករហូប ពេលទៅដល់ខ្លួនក៏បានអង្វរគាត់សុំលុយគាត់ចំនួន ៥.០០០៛០០ ដើម្បីយកទៅទិញអង្ករ គាត់ថា គ្មានពេលនោះខ្លួនសំឡឹងមើលក្នុងហោប៉ៅអាវគាត់មានលុយ ខ្លួនក៏បានកោរពុកមាត់ ដោយយកផ្លែឡាមដាក់ខ្ទាស់ក្នុងចង្អុលដៃ ហើយកោរពុកមាត់បណ្តើរ និងសុំលុយគាត់បណ្តើរ ខ្លួនក៏យកក្បាលរបស់ខ្លួនរុលចូលទៅលើដើមទ្រូងរបស់គាត់បណ្តើរក្នុងលក្ខណៈប្រឡែងលែងជាមួយប្រពន្ធ ភ្លេចគិតផ្លែឡាមនៅនិងដៃ បណ្តាលឱ្យមុតត្រូវចំដោះខាងស្តាំរបស់គាត់ជាច្រើនកន្លែងមានឈាមពេញខ្លួន ខ្លួនភ័យពេករត់គេចខ្លួន តែត្រូវសមត្ថកិច្ចចាប់ខ្លួនបាននៅថ្ងៃនោះតែម្តង ។

-ឈ្មោះ **អ ម** ជាជនរងគ្រោះឆ្លើយថា កាលមុនតុលាការបានកាត់ទោសប្តីខ្លួនម្តងរួចទៅហើយ តែកាត់កំបាំងមុខខ្លួន ខ្លួនសុំឱ្យតុលាការកាត់សេចក្តីឡើងវិញ និង នៅចំពោះមុខខ្លួនផង ។ ខ្លួនសុំបញ្ជាក់ថា ប្តីខ្លួនបានប្រព្រឹត្តបង្ករបួសមកលើខ្លួនដោយចេតនាពិតប្រាកដមែន គាត់គ្មានធ្វើលេង ឬ ប្រឡែងដូចគាត់ថានោះឡើយ ពេលនោះខ្លួនបានប្តឹងឱ្យសមត្ថកិច្ចធ្វើតាមច្បាប់សិន ដើម្បីឱ្យគាត់ខ្លាចផ្លូវច្បាប់ ព្រោះកន្លងមកគាត់បានរំលោភលើសិទ្ធិនារីធ្វើបាបប្រពន្ធកូនជាច្រើនលើកច្រើនសារ លើកនេះក៏ធ្វើបាបខ្លួនទៀត គឺយកផ្លែឡាមមកវះដោះខាងស្តាំបណ្តាលឱ្យមានរបួសប្រហែល ១០ សម និង ជម្រៅ ២សម ឥឡូវនេះគាត់បានរស់នៅក្នុងគុកមួយរយៈឃើញថា ខិតខំលត់ដំកសាងខ្លួន និងបានសន្យាជាមួយខ្លួនថា ឈប់ប្រព្រឹត្តអំពើរំលោភលើប្រពន្ធកូនទៀតហើយ ហេតុនេះសុំឱ្យតុលាការជួយសំរាលទោសឱ្យប្តីខ្លួន ព្រោះគ្មាននរណាបើករថយន្តឈ្នួលរកស៊ីចិញ្ចឹមកូនប្រពន្ធ និង ម្តាយចាស់ជរា នៅពេលដែលគាត់ជាប់គុកគឺខ្លួនវេទនាយ៉ាងខ្លាំងសឹងតែមានបាយហូបក៏គ្មានដែរ ហេតុនេះសុំតុលាការអនុគ្រោះ ត្រាប្រណីដល់ប្តីខ្លួនផង ។ លើកមុនខ្លួនទាមទារសំណងជម្ងឺចិត្ត ថ្លៃថ្នាំព្យាបាលរបួសមែន ឥឡូវនេះខ្លួនក៏ឈប់ទាមទារទៀតដែរ ព្រោះប្តីខ្លួនគ្មានលទ្ធភាពឡើយ ។

-ឈ្មោះ **ម គន្ធ** ជាសាក្សីបានឆ្លើយថា ឈ្មោះ **ហ ចន** និង **អ ម** ជាប្តីប្រពន្ធគ្នាមែន ប៉ុន្តែកន្លងមកប្តីប្រពន្ធគេនេះឧស្សាហ៍ឈ្លោះខ្លាំងណាស់ឃើញតែប្រពន្ធរបួសជាច្រើនលើកច្រើនសារ ខ្លួនដឹងថា មុនពេលកើតហេតុប្តី

CS CamScanner

ប្រពន្ធគេនេះឈ្មោះគ្លា គឺប្តីបានប្រើអំពើហិង្សាទៅលើប្រពន្ធ និង កូន ជាហេតុធ្វើឱ្យប្រពន្ធទ្រាំលែងបាន និង ភ័យខ្លាចក៏រត់មកស្នាក់នៅជាមួយខ្លួនអស់រយៈពេលជាយូរថ្ងៃ ។ ខ្លួននៅចាំបានថា មានថ្ងៃមួយប្រហែលជាម៉ោង ០៥ល្ងាចស្រាប់តែឃើញប្តីគាត់មកដល់ផ្ទះខ្លួននៅពេលរសៀលថា សុំលុយពីប្រពន្ធចំនួន ១.០០០៛០០ ដើម្បីទិញថ្នាំជក់ តែប្រពន្ធមិនឱ្យហើយមិនដឹងថា ប្រពន្ធគាត់ឱ្យប៉ុន្មានទេ ខ្លួនដើរទៅចម្ការមិនដឹងថា ប្តីគាត់បានប្រព្រឹត្តអ្វីទៅលើប្រពន្ធនោះដែរស្រាប់តែឮសម្លេងគាត់ស្រែកជួយផងៗ ខ្លួនរត់មកមើល ឃើញប្រពន្ធគាត់មានឈាមពេញខ្លួននៅដើមទ្រូងប្តីគាត់ភ័យពកក៏រត់គេចខ្លួនបាត់ទៅ ឯខ្លួននាំប្រពន្ធគាត់ទៅព្យាបាលនៅមន្ទីរពេទ្យ ឃើញមានរបួសនៅដោះជាច្រើនកន្លែង បន្ទាប់មត្ថកិច្ចក៏ចាប់ប្តីគាត់បាន ។ សព្វថ្ងៃនេះខ្លួនឃើញប្រពន្ធគាត់វេទនាណាស់ គ្មានលុយកាក់ គ្មានបាយហូប មកហូបនៅជាមួយខ្លួន ព្រមទាំងកូន និង ម្តាយ ផ្ទះគាត់បិទទ្វារចោលទៀតផង ។ ឯរឿងរ៉ាវអ្វីផ្សេងទៀតខ្លួនមិនដឹងឡើយ ។

-បានឃើញលិខិតរបស់គ្លីនិកសេតបញ្ជាក់ថា ឈ្មោះ **អ ម** ភេទស្រី អាយុ ៥០ឆ្នាំ ជាប្រជាជនរស់នៅក្រុម ១៥ ភូមិ ២ សង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ បានសំរាកព្យាបាលរបួសចំនួន ១០ថ្ងៃអស់ទឹកប្រាក់ចំនួន ២៥០.០០០៛០០ និង $៧២.៥០ ដែលមានរោគវិនិច្ឆ័យ Plaie du Sein droit par arm blance ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ **ឃ ចន** ពីបទបង្ករបួសដោយចេតនា ប្រព្រឹត្តនៅសង្កាត់ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ហេតុនេះសុំឱ្យតុលាការពិចារណាទៅតាមផ្លូវច្បាប់ដោយអនុគ្រោះ ។

-មេធាវីបានធ្វើសេចក្តីសន្និដ្ឋានការពារថា កូនក្តីខ្លួនកន្លងមកបានប្រើអំពើហិង្សាទៅលើប្រពន្ធកូនមែន តែដល់ពេលជាប់ពន្ធនាគារ ឃើញគាត់មានការសោកស្តាយកំហុសស្មានតែថា វាយប្រពន្ធកូនដូចជាធម្មតា ព្រោះតែការពិចារណាមិនបានដិតដល់ គាត់ជួបលំបាកច្រើន លុយគ្មាន ចេះតែមួរម៉ៅ ភ្លេចគិតអ្វីៗទាំងអស់បានជាជ្រុលជ្រួសទៅលើប្រពន្ធយ៉ាងដូច្នេះ ឥឡូវនេះគាត់ដឹងខ្លួន សន្យាថានឹងឈប់ប្រព្រឹត្តទៅលើប្រពន្ធកូនរបស់គាត់ទៀត ឯប្រពន្ធគាត់ក៏ថាឈប់ប្តឹងពីប្តីគាត់តទៅទៀតដែរ និង សុំឱ្យតុលាការដោះលែងប្តីគាត់ ដើម្បីជួបជុំគ្នាក្នុងការរកស៊ីចិញ្ចឹមគ្នា និង កូនព្រមទាំងម្តាយតទៅទៀត សូម្បីតែសាក្សីក៏បានបញ្ជាក់ដែរថា ប្រពន្ធកូន និង ម្តាយជនរងគ្រោះកាន់តែវេទនាទៅៗ និងគ្មានអង្ករច្រកឆ្នាំង ដូច្នេះសុំឱ្យតុលាការយោគយល់ អធ្យាស្រ័យត្រាប្រណីដល់កូនក្តីរបស់ខ្លួនដោយក្តីអនុគ្រោះផង ។

-ឈ្មោះ **ឃ ចន** ជាជនជាប់ចោទបានឆ្លើយសំដីចុងក្រោយបង្អស់ថា ខ្លួនមានការសោកស្តាយយ៉ាងខ្លាំងមិនគួរណាធ្វើបាបប្រពន្ធកូនយ៉ាងដូច្នេះទេ ខ្លួនសន្យាថា ឈប់ប្រព្រឹត្តអំពើយ៉ាងដូច្នេះទៀតហើយ នៅពេលខ្លួនរស់នៅក្នុងគុកខ្លួនដឹងច្បាស់ថា ប្រពន្ធកូន និង ម្តាយច្បាស់ជាវេទនាហើយ គឺគ្មាននរណារកស៊ីចិញ្ចឹមទេ ពេលប្រពន្ធខ្លួនគាត់ខឹងគាត់ប្តឹងពីខ្លួន តែខ្លួនរស់នៅក្នុងគុកមិនបានប៉ុន្មានថ្ងៃផង គាត់ក៏ឧស្សាហ៍ទៅមើលខ្លួនជាញឹកញាប់ ហើយគាត់ប្រាប់ខ្លួនថា គាត់ឈប់ប្តឹងពីខ្លួនទៀតហើយ ។ ហេតុនេះឱ្យតុលាការមេត្តាយោគយល់នូវគំនិតរបស់ខ្លួន និង ប្រពន្ធខ្លួនព្រមទាំងមេធាវីរបស់ខ្លួន ដែលបានសុំដោយទទូចហើយទទូចទៀត ក្នុងការឱ្យខ្លួនវិលត្រឡប់ទៅជួបប្រពន្ធកូនក្នុងការរកស៊ីចិញ្ចឹមគ្នាតទៅទៀត ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីស្តាប់ចម្លើយជនរងគ្រោះ

-ក្រោយពីស្តាប់ចម្លើយសាក្សី

-ក្រោយពីបានពិនិត្យភស្តុតាង

-ក្រោយពីបានឃើញសាលក្រមកំបាំងមុខលេខ ១០៥ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៤

CamScanner

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានទោសរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពារមេធាវី

-ក្រោយពីបានស្តាប់សំដីចុងក្រោយបង្អស់របស់ជនជាប់ចោទ

## តុលាការក្រុងព្រះសីហនុ

-ក្រោយពីបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## យល់ឃើញថា

-ជនជាប់ចោទ និង ជនរងគ្រោះ គឺជាប្តីប្រពន្ធនឹងគ្នា ពីរនាក់នេះនៅមានមនោសញ្ចេតនានឹងគ្នានៅឡើយ ។

-ជនជាប់ចោទបានអះអាងថា ដោយសាររថយន្តខូច និង គ្មានលុយទិញបាយទឹកហូប ក៏ទៅសុំលុយពីប្រពន្ធ តែទៅដល់ខ្លួនបានយកផ្លែឡាមកោរពុកមាត់បណ្តើរ និង យកក្បាលរុលដើមទ្រូងប្រពន្ធបណ្តើរ និង យកដៃកាន់ផ្លែឡាមលូកហោប៉ៅអាវប្រពន្ធ ដើម្បីយកលុយចេញពីហោប៉ៅអាវ ភ្លេចគិតពីផ្លែឡាមនៅនឹងដៃបណ្តាលឱ្យមុតដើមទ្រូងប្រពន្ធត្រូវចំដោះជាច្រើនកន្លែង ដូច្នេះជនជាប់ចោទថា គ្មានចេតនាក្នុងការប្រព្រឹត្តនោះទេ ។ តែបើតាមគំនិតរបស់ជនជាប់ចោទ គឺខឹងនឹងប្រពន្ធជាយូរមកហើយ សុំលុយមិនបានប្រពន្ធរត់ទៅនៅផ្ទះបងប្អូនគ្មានបាយហូប ក៏មានកំហឹងនឹងប្រពន្ធ ដូច្នេះការប្រព្រឹត្តនេះ គឺពិតជាមានចេតនាប្រាកដមែន ។

-សាលក្រមកំបាំងមុខលេខ ១០៥ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០៤ របស់តុលាការក្រុងព្រះសីហនុ ដែលបានសំរេចដាក់ពន្ធនាគារកំណត់ ០៧ខែ និង ឱ្យសងប្រាក់ចំនួន ០២លានរៀល ទៅជនរងគ្រោះ តែសាលក្រមនេះត្រូវបានជនរងគ្រោះប្តឹងទាស់ និង សុំឱ្យតុលាការសំរេចឡើងវិញ នៅចំពោះមុខជនរងគ្រោះ ដូច្នេះតុលាការពិចារណាបញ្ហានេះ ។

-ក្នុងពេលសវនាការនេះជនរងគ្រោះបានសុំអង្វរក និង សុំឱ្យតុលាការដោះលែងប្តីខ្លួនឱ្យមានសិទ្ធិសេរីភាពឡើងវិញ ជនរងគ្រោះពេលមានកំហឹងឈឺចាប់ គឺសំណូមពរឱ្យតុលាការផ្តន្ទាទោស និង ទារសំណងព្រមទាំងជម្ងឺចិត្ត ពេលវេទនាសុំឱ្យតុលាការជួយដោះលែងប្តី ដើម្បីទៅរកស៊ីចិញ្ចឹមជីវិតតទៅទៀត ។

-ជនជាប់ចោទមានការសោកស្តាយនៅកំហុសរបស់ខ្លួន ហើយសន្យាថា ឈប់ប្រព្រឹត្តអំពើមិនគប្បីទៅលើប្រពន្ធ និង កូនទៀតហើយ និង សុំឱ្យតុលាការអធ្យាស្រ័យ និង យោគយល់ ។

-ការឈប់ទាមទារសំណងរបស់ជនរងគ្រោះនោះ គឺថា សិទ្ធិរបស់គាត់មិនប៉ះពាល់ដល់ផលប្រយោជន៍សង្គមឡើយ គឺមានលក្ខណៈសមស្របតាមផលប្រយោជន៍របស់ពួកគេ និង ធានាបានការសាមគ្គីរាប់អានគ្នាជាប្តីប្រពន្ធតទៅអនាគតទៀត ។

-ជនជាប់ចោទសព្វថ្ងៃនៅក្នុងពន្ធនាគារមានការលត់ដំកសាងខ្លួន ហើយជនជាប់ចោទមានការឃុំខ្លួនអស់រយៈពេលយូរមកហើយដែរ ។

-ការបង្ករបួស ឬ ប្រើអំពើហិង្សាទៅលើប្រពន្ធកូនមិនមែនចាត់ទុកជាធម្មតានោះទេ ព្រោះមនុស្សម្នាក់១ គឺជាពលរដ្ឋដូចគ្នា មានសិទ្ធិដូចគ្នា មានសិទ្ធិស្មើភាពនៅចំពោះមុខច្បាប់ដូចគ្នា អ្នកណាក៏ដោយឱ្យតែបង្ករបួសដោយចេតនាទៅលើអ្នកដទៃ មិនថាទៅលើមនុស្សស្រី ប្រុស កុមារ កុមារី គឺត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ទាំងអស់គ្នា ។ ជាក់ស្តែងដូចជាករណីលើឈ្មោះ **ហា ចន** បានប្រើហិង្សាទៅលើកូនប្រពន្ធ ជាច្រើនលើកច្រើនសារ និង បង្ករបួសទៅលើប្រពន្ធចំដោះទៀត សុទ្ធតែជាការគ្រោះថ្នាក់ដល់អាយុជីវិត ហេតុនេះហើយឈ្មោះនេះត្រូវទទួលទោសតាមផ្លូវច្បាប់ផងដែរ ។

CS CamScanner

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ ម៉ា ចន ពីបទបង្ករបួសដោយចេតនា ប្រព្រឹត្តនៅសង្កាត់ ៣ ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ ដែលច្បាប់តម្រូវឱ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

**ហេតុដូច្នេះតុលាការក្រុងព្រះសីហនុ**

**សំរេច :**

**ផ្តន្ទាទោស :**

១-បដិសេធសេចក្តីសំរេចនៃសាលក្រមកំបាំងមុខលេខ ១០៥ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០០៤ របស់តុលាការក្រុងព្រះសីហនុ ចោលជាអសារបង់គិតចាប់តាំងពីថ្ងៃនេះតទៅ ។

២-ផ្តន្ទាទោសឈ្មោះ **ម៉ា ចន** ភេទប្រុស អាយុ ៥០ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៦ខែកន្លះ ( ប្រាំមួយខែកន្លះ ) គិតពីថ្ងៃចាប់ខ្លួនថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ ។

ពីបទបង្ករបួសដោយចេតនា ប្រព្រឹត្តនៅសង្កាត់លេខ ៣ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ កាលពីថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ឱ្យផ្តន្ទាទោសតាមមាត្រា ៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈនៅចំពោះមុខជនជាប់ចោទ ជនរងគ្រោះ បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងអំឡុងច្បាប់ ។

**ក្រឡាបញ្ជី** [redacted]

**ចៅក្រមជំនុំជំរះ** [redacted]